ក្រសួងមហាផ្ទៃ




# សៀវភៅណែនាំ
# ស្តីពី
# ការគ្រប់គ្រងដំណើរការអប់រំឪពុកម្តាយ អាណាព្យាបាល ក្នុងការគាំពារ និងអភិវឌ្ឍន៍កុមារតូច សម្រាប់ឃុំ សង្កាត់

ខែមីនា ឆ្នាំ២០២២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខៈ ១៣០៦២ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីការគ្រប់គ្រងដំណើរការអប់រំឪពុកម្តាយ អាណាព្យាបាល ក្នុងការគាំពារ និងអភិវឌ្ឍន៍កុមារតូចសម្រាប់ឃុំ សង្កាត់

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ២២ អនក្រ.បកចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការផ្ទេរវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងប្រកាសលេខ៤២៧៥ ប្រ.ក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ នៅក្នុងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

- យោងប្រកាសលេខ៣៨៤០ ប្រក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់
- យោងតាមសំណើរបស់អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ

# សម្រេច

**ប្រការ១.-**

ដាក់ឱ្យប្រើប្រាស់នូវសៀវភៅណែនាំស្តីពីការគ្រប់គ្រងដំណើរការអប់រំឪពុកម្តាយ អាណាព្យាបាល ក្នុងការគាំពារ និងអភិវឌ្ឍន៍កុមារតូចសម្រាប់ឃុំ សង្កាត់។

**ប្រការ២.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ បុគ្គលិកឃុំ សង្កាត់ មន្ត្រីរាជការដែលមានភារកិច្ចគាំទ្រដល់រដ្ឋបាលឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធនានា ត្រូវអនុវត្តតាមគោលការណ៍ បែបបទ និងនីតិវិធីនានាដែលបានកំណត់នៅក្នុងសៀវភៅណែនាំនេះ ក្នុងការអនុវត្ត និងការគ្រប់គ្រងដំណើរការអប់រំឪពុកម្តាយ អាណាព្យាបាល ក្នុងការគាំពារ និងអភិវឌ្ឍន៍កុមារតូចសម្រាប់ឃុំ សង្កាត់។

**ប្រការ៣.-**

សេចក្តីសម្រេចនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ...ចន្ទ ៩ រោច.......ខែ...ចេត្រ.....ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...២៥...ខែ...មេសា.....ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល ÷**

- ក្រសួងស្ថាប័នជាសមាជិក គ.ជ.អ.ប
- លេខាធិការដ្ឋាន គ.ជ.អ.ប
- អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត
- រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- រដ្ឋបាលឃុំ សង្កាត់
- ឯកសារ-កាលប្បវត្តិ

# មាតិកា


សេចក្តីផ្តើម................................................................................................ ១

ជំពូកទី១៖ ការរៀបចំផែនការសកម្មភាព និងថវិកា.................................................................... ៣

១.១. ការវិភាគស្ថានភាព.................................................................................................៤

១.២. ការរៀបចំផែនការសកម្មភាព និងថវិកា .......................................................................... ១១

ជំពូកទី២៖ ដំណើរការនៃការអប់រំឪពុកម្តាយ អាណាព្យាបាល.......................................... .......១៥

២.១. ការបង្កើតគណៈកម្មការគ្រប់គ្រងគម្រោង សកម្មភាពអប់រំឪពុកម្តាយ អាណាព្យាបាល............. .. ១៨

២.២. ការជ្រើសរើសឪពុកម្តាយបង្គោល......................................................................................២២

២.៣. ការជ្រើសរើសអ្នកសម្របសម្រួល......................................................................................២៥

២.៤. ការចងក្រងក្រុមឪពុកម្តាយ អាណាព្យាបាល.........................................................................២៥

២.៥. ការបណ្តុះបណ្តាលឪពុកម្តាយបង្គោល និងអ្នកសម្របសម្រួល..................................................២៦

ជំពូកទី៣៖ ការតាមដាន ត្រួតពិនិត្យ និងការរៀបចំរបាយការណ៍.......................................... ២៨

៣.១. ការតាមដាន ត្រួតពិនិត្យ ..............................................................................................៣១

៣.២. ការរៀបចំរបាយការណ៍.................................................................................................៣១

ជំពូកទី៤៖ យន្តការគាំទ្រគម្រោង...................................................................................... ៣៦

៤.១. រដ្ឋបាលរាជធានី ខេត្ត ..................................................................................................៣៩

៤.២. មន្ទីរអប់រំ យុវជន និងកីឡា.............................................................................................. ៤០

៤.៣. មន្ទីរកិច្ចការនារី ............................................................................................................. ៤០

៤.៤. មន្ទីរសុខាភិបាល ........................................................................................................... ៤០

៤.៥. មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា..................................................................... ៤០

៤.៦. រដ្ឋបាលក្រុង ស្រុក ខណ្ឌ......................................................................................................៤២

៤.៧. ការិយាល័យអប់រំ យុវជន និងកីឡា .......................................................................................៤២

៤.៨. ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម .......................................................................៤៣

៤.៩. ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល ....................................................................................៤៣

៤.១០. ប្រជាពលរដ្ឋ ...................................................................................................................៤៣

# សេចក្ដីផ្ដើម

រាជរដ្ឋាភិបាលកម្ពុជាមានចក្ខុវិស័យយ៉ាងច្បាស់លាស់ក្នុងការលើកកម្ពស់សេវាគាំពារ និងអភិវឌ្ឍន៍កុមារតូច ជាពិសេសកុមារតូចរងគ្រោះ កុមារតូចងាយរងគ្រោះ និងកុមារស្ថិតក្នុងគ្រួសារក្រីក្រ ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ជាមួយគ្នានេះ គោលនយោបាយជាតិស្ដីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច មានគោលបំណងធានាឱ្យកុមារតូចចាប់ពី០ឆ្នាំរហូតដល់អាយុក្រោម៦ឆ្នាំ ទទួលបានសេវាសម្រាប់ការគាំពារ និងអភិវឌ្ឍន៍ពេញលេញលើគ្រប់ផ្នែក និងធានាឱ្យក្រសួង ស្ថាប័ន សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍នានាសហការគ្នាសម្រាប់ការគាំពារ និងអភិវឌ្ឍន៍កុមារតូច។

តាមរបាយការណ៍របស់មូលនិធិសហប្រជាជាតិដើម្បីកុមារ ហៅកាត់យូនីសេហ្វ (UNICEF) បានបង្ហាញថា កុមារប្រហែល ៤៣% នៃកុមារអាយុក្រោម៥ឆ្នាំក្នុងប្រទេសកំពុងអភិវឌ្ឍន៍ប្រឈមនឹងគ្រោះថ្នាក់ធ្ងន់ធ្ងរទាក់ទងនឹងការមិនទទួលបានការអភិវឌ្ឍ និងការរីកលូតលាស់ប្រកបដោយសក្ដានុពលពេញបរិបូណ៌ដោយសារភាពក្រីក្រ ការកង្វះអាហារូបត្ថម្ភ ការកង្វះការអប់រំ និងការមិនទទួលបានឱកាសមើលថែទាំបានជិតដល់ពីឪពុកម្ដាយអាណាព្យាបាល។

ដូច្នេះការអប់រំថែទាំចិញ្ចឹមបីបាច់កុមារតូចអាយុក្រោម៦ឆ្នាំឱ្យបានល្អពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការអភិវឌ្ឍខួរក្បាលរបស់កុមារតូច និងមានអត្ថប្រយោជន៍ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរយៈពេលវែងជាវិជ្ជមានសម្រាប់ប្រទេសជាតិ ព្រោះថាកុមារជាទំពាំងស្នងឫស្សីដែលនឹងក្លាយជាអ្នកបន្តវេនក្នុងពេលអនាគត។ ការអភិវឌ្ឍជំនាញ និងបំណិនជីវិតសម្រាប់កុមារនៅដំណាក់កាលដំបូងនៃជីវិតរបស់ពួកគេនឹងជួយរៀបចំពួកគេសម្រាប់ភាពជោគជ័យនៅពេលកុមារឈានជើងចូលសាលារៀន និងចូលទៅក្នុងសង្គម។ ក្នុងនោះផងដែរ ការប្រើប្រាស់បច្ចេកវិទ្យាដែលសមស្របទៅតាមអាយុរបស់កុមារអាចជួយបង្កើតការរៀនសូត្រឱ្យកាន់តែល្អប្រសើរ និងមានប្រសិទ្ធភាព។ ការអនុញ្ញាតឱ្យកុមារតូចសម្រេចបាននូវសក្ដានុពលនៃការអភិវឌ្ឍពេញលេញ គឺជាការផ្ដល់ជូននូវសិទ្ធិកុមារពិតប្រាកដ និងតម្រូវការចាំបាច់សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។

វិស័យសុខាភិបាលក៏មានតួនាទីដ៏សំខាន់ក្នុងការគាំទ្រដល់ការចិញ្ចឹមបីបាច់ និងថែទាំកុមារក្នុងជីវិតដំបូងរបស់ពួកគេតាមរយៈការអន្តរាគមន៍ជាប្រចាំសម្រាប់សុខភាពមាតា និងទារក រួមទាំងអាហារូបត្ថម្ភ សុខភាពផ្លូវចិត្ត និងការការពារពីជំងឺឆ្លងផ្សេងៗ។ ជាមួយគ្នានេះ វិស័យអប់រំមានតួនាទីដ៏សំខាន់ក្នុងការកសាងធនធានមនុស្សនិងរៀបចំគម្រោងសកម្មភាពអប់រំពីការថែទាំនិងការចិញ្ចឹមបីបាច់កុមារដល់ឪពុកម្ដាយអាណាព្យាបាល។

ក្នុងឆ្នាំ២០២០ អង្គការសុខភាពពិភពលោកបានដាក់ចេញនូវគោលការណ៍លើកកម្ពស់ការគាំពារ និងអភិវឌ្ឍន៍កុមារតូចរួមមាន សុខភាព អាហារូបត្ថម្ភ តម្រូវការឆ្លើយតបពីអ្នកថែទាំ ការសិក្សាក្នុងដំណាក់កាលដំបូង រួមទាំងសន្តិសុខ និងសុវត្ថិភាព។




សៀវភៅណែនាំស្តីពីការគ្រប់គ្រងដំណើរការអប់រំឪពុកម្តាយ អាណាព្យាបាលក្នុងការគាំពារ និងអភិវឌ្ឍន៍កុមារតូចឃុំ សង្កាត់ មានគោលបំណងឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ប្រើប្រាស់ជាមូលដ្ឋានក្នុងការរៀបចំ និងគ្រប់គ្រងដំណើរការ និងការអនុវត្តសកម្មភាពអប់រំឪពុកម្តាយ អាណាព្យាបាលក្នុងការគាំពារ និងអភិវឌ្ឍន៍កុមារតូចអាយុក្រោម៦ឆ្នាំ ប្រកបដោយប្រសិទ្ធភាព តម្លាភាព សមធម៌ និងបរិយាប័ន្ន។

សៀវភៅណែនាំនេះបរិយាយអំពីដំណាក់កាលនៃការរៀបចំការគ្រប់គ្រងដំណើរការនិងការអនុវត្តសកម្មភាពអប់រំឪពុកម្តាយ អាណាព្យាបាល នៅតាមឃុំ សង្កាត់ ដោយចែកចេញជា៤ជំពូក។

**សៀវភៅណែនាំនេះ ចែកចេញជា ៤ជំពូក ដែលក្នុងនោះមាន៖**

**ជំពូកទី១ ការរៀបចំផែនកាសកម្មភាព និងថវិកា**

**ជំពូកទី២ ដំណើរការនៃការអប់រំឪពុកម្តាយ អាណាព្យាបាល**

**ជំពូកទី៣ ការតាមដាន ត្រួតពិនិត្យ និងការរៀបចំរបាយការណ៍**

**ជំពូកទី៤ យន្តការគាំទ្រគម្រោងសកម្មភាពអប់រំឪពុកម្តាយ អាណាព្យាបាល**

# ជំពូកទី១

# ការរៀបចំផែនការសកម្មភាព និងថវិកា




រូបភាព ការប្រជុំវិភាគស្ថានភាព រៀបចំផែនការសកម្មភាព និងផែនការរបស់រដ្ឋបាលឃុំអូស្វាយ
ស្រុកកំពង់សៀម ខេត្តកំពង់ចាម

# ជំពូកទី១
# ការរៀបចំផែនការសកម្មភាព និងថវិកា

ការអប់រំឪពុកម្តាយ អាណាព្យាបាលស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូចអាយុក្រោម៦ឆ្នាំ គឺជាការងារមួយដ៏ចាំបាច់ដែលតម្រូវឱ្យអ្នកពាក់ព័ន្ធទាំងអស់ ជាពិសេសក្រុមប្រឹក្សាឃុំ សង្កាត់ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (គ.ក.ន.ក.)។ ដើម្បីអនុវត្តកិច្ចការងារនេះ រដ្ឋបាលឃុំ សង្កាត់ត្រូវធ្វើការវិភាគស្ថានភាព និងរៀបចំផែនការសកម្មភាព និងថវិកាសម្រាប់ការអប់រំឪពុកម្តាយ អាណាព្យាបាលស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូចអាយុក្រោម៦ឆ្នាំ តាមសកម្មភាពដូចខាងក្រោម៖

- ប្រមូលទិន្នន័យគ្រួសារដែលមានកុមារតូចអាយុក្រោម៦ឆ្នាំ
- ពិនិត្យស្ថានភាព និងទីតាំងសម្រាប់អនុវត្តសកម្មភាព
- កំណត់បញ្ហា និងដំណោះស្រាយ
- រៀបចំសកម្មភាពអាទិភាពសម្រាប់គម្រោង។

**សម្គាល់៖** គ្រប់សកម្មភាព ដែលបានរៀបរាប់ខាងលើត្រូវស្របតាមដំណើរការនៃការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលឃុំ សង្កាត់។

ដើម្បីឱ្យគម្រោងសកម្មភាពនានាពាក់ព័ន្ធនឹងការអប់រំឪពុកម្តាយ អាណាព្យាបាលស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូចអាយុក្រោម៦ឆ្នាំអាចអនុវត្តទៅបានរដ្ឋបាលឃុំសង្កាត់ត្រូវបញ្ចូលគម្រោងសកម្មភាពទាំងនេះទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំ សង្កាត់ (ករណីគម្រោងមានការសន្យាគាំទ្រ)។ ក្នុងករណីដែលក្រុមប្រឹក្សាឃុំ សង្កាត់ សម្រេចអនុវត្តគម្រោងសកម្មភាពនេះដោយប្រើប្រាស់មូលនិធិឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការវិភាជន៍ថវិកាឃុំ សង្កាត់ ដោយឆ្លុះបញ្ចាំងគម្រោងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់។

## ១.១. ការវិភាគស្ថានភាព

ការវិភាគស្ថានភាពមានគោលបំណងកំណត់បញ្ហា និងតម្រូវការសម្រាប់រៀបចំ និងអនុវត្តគម្រោងសកម្មភាពអប់រំឪពុកម្តាយ អាណាព្យាបាលតាមភូមិ ដែលមានកូនអាយុក្រោម៦ឆ្នាំ តាមសកម្មភាពដូចខាងក្រោម៖

- **ការប្រមូលទិន្នន័យគ្រួសារ ដែលមានកុមារតូចអាយុក្រោម៦ឆ្នាំ៖** អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (អ.ក.ន.ក.) ត្រូវប្រមូលទិន្នន័យគ្រួសារដែលមានកុមារតូចពី០ឆ្នាំ (ទារកក្នុងផ្ទៃ) ដល់អាយុក្រោម៦ឆ្នាំ ដែលមាននៅតាមភូមិនីមួយៗនៅក្នុងឃុំ សង្កាត់របស់ខ្លួន។ ទិន្នន័យនេះអាចយកបានពីមេភូមិ និងអនុប្រធានភូមិ ដោយផ្អែកលើទិន្នន័យក្នុងផែនទីសេវាសង្គមភូមិ ឬសៀវភៅទិន្នន័យភូមិ ឬទិន្នន័យឃុំ សង្កាត់ ឬសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត ឬប័ណ្ណលឿងចាក់

រាក់សាំង ឬប្រភពទិន្នន័យផ្សេងទៀត។ (ទម្រង់ទី១៖ ទិន្នន័យគ្រួសារ ដែលមានកុមារអាយុក្រោម៦ឆ្នាំ ដែលត្រូវចងក្រងជាក្រុមឪពុកម្តាយ អាណាព្យាបាល ដើម្បីទទួលបានការអប់រំ)។

- **ពិនិត្យស្ថានភាព និងទីតាំងសម្រាប់អនុវត្តសកម្មភាព៖** អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ សហការជាមួយសមាជិកគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (គ.ក.ន.ក.) ជាពិសេសមេភូមិចុះពិនិត្យសកម្មភាពការងារគម្រោងសកម្មភាពអប់រំឪពុកម្តាយ ដែលមានកុមារតូចអាយុក្រោម៦ឆ្នាំ ដើម្បីពិនិត្យលទ្ធភាពក្នុងការបង្កើតចំនួនក្រុមឪពុកម្តាយបង្គោលតាមតម្រូវការ។
- **ការកំណត់បញ្ហា និងដំណោះស្រាយ (ថ្នាក់ភូមិ)៖** អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (អ.ក.ន.ក.) ត្រូវពិភាក្សាជាមួយសមាជិកផ្សេងទៀតរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (គ.ក.ន.ក.) ដើម្បីពិនិត្យពីបញ្ហាប្រឈម និងដំណោះស្រាយនានាពាក់ព័ន្ធនឹងការអប់រំឪពុកម្តាយ អាណាព្យាបាលនៅក្នុងឃុំ សង្កាត់។ ករណីឃុំ សង្កាត់ធ្លាប់មានគម្រោងសកម្មភាពអប់រំឪពុកម្តាយ អាណាព្យាបាលនៅតាមភូមិរួចហើយ អ្នកទទួលបន្ទុកកិច្ចការនារី និង កុមារឃុំ សង្កាត់ (អ.ក.ន.ក.) ត្រូវស្រង់បញ្ហាប្រឈម និងដំណោះស្រាយនៃការអនុវត្តគម្រោងសកម្មភាពអប់រំឪពុកម្តាយ អាណាព្យាបាលកន្លងមក សម្រាប់កែលម្អគម្រោងសកម្មភាពអប់រំឪពុកម្តាយ អាណាព្យាបាលឱ្យបានកាន់តែប្រសើរ (ទម្រង់ទី២៖ គំរូតារាងបញ្ហា និងដំណោះស្រាយ សម្រាប់គម្រោងសកម្មភាពអប់រំឪពុកម្តាយ អាណាព្យាបាល)។
- **រៀបចំសកម្មភាពអាទិភាពសម្រាប់គម្រោង៖** អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់សហការជាមួយសមាជិកគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (គ.ក.ន.ក.) ក្នុងឃុំ សង្កាត់ ឬមេភូមិពិនិត្យមើលសកម្មភាពទាំងឡាយដែលបានអនុវត្ត និងចាត់អាទិភាពការងារ អប់រំសម្រាប់ឪពុកម្តាយអំពីការគាំពារ និងអភិវឌ្ឍន៍កុមារតូចអាយុក្រោម៦ឆ្នាំ ដើម្បីដាក់បញ្ចូលទៅក្នុងគម្រោងសកម្មភាពអាទិភាពផ្នែកសេវាសង្គមឃុំ សង្កាត់ ជាពិសេសក្នុងគម្រោងសកម្មភាពវិនិយោគបីឆ្នាំរំកិលរបស់ឃុំ សង្កាត់។ បន្ទាប់មក ប្រធាន គ.ក.ន.ក. និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ពិភាក្សាជាមួយគណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់ (គ.ផ.ថ.) ស្មៀនឃុំ សង្កាត់ ដើម្បីដាក់បញ្ចូលបញ្ហា និងដំណោះស្រាយដែលបានរកឃើញទៅក្នុងដំណើរការ កសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំ សង្កាត់ (ទម្រង់ទី៣៖ គំរូតម្រូវ ការសកម្មភាពអាទិភាពនៃគម្រោងសកម្មភាពអប់រំឪពុកម្តាយ អាណាព្យាបាល ក្នុងការគាំពារ និងអភិវឌ្ឍន៍កុមារតូចអាយុក្រោម៦ឆ្នាំ)។

ទម្រង់ទី១

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត...................

ក្រុង ស្រុក ខណ្ឌ................

ឃុំ សង្កាត់ ......................

**ទិន្នន័យគ្រួសារដែលមានកុមារអាយុក្រោម៦ឆ្នាំ ដែលត្រូវចងក្រងជាក្រុមឪពុកម្ដាយ អាណាព្យាបាល ដើម្បីទទួលបានការអប់រំ ឆ្នាំ២០.......**

| ល.រ | ឈ្មោះភូមិ | ០ឆ្នាំ | | ១ឆ្នាំ | | ២ឆ្នាំ | | ៣ឆ្នាំ | | ៤ឆ្នាំ | | ៥ឆ្នាំ | | ០-២ឆ្នាំ | | ៣-៥ឆ្នាំ | | ០-៥ឆ្នាំ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | | | | | | | | | | | | | | | | | | | |
| ២ | | | | | | | | | | | | | | | | | | | |
| ៣ | | | | | | | | | | | | | | | | | | | |
| **សរុបរួម** | | | | | | | | | | | | | | | | | | | |

ថ្ងៃ.........................ខែ..................ឆ្នាំ..............ព.ស............

ថ្ងៃទី...........ខែ..............ឆ្នាំ..............

**អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់**

**ទម្រង់ទី២**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជធានី ខេត្ត....................**
**ក្រុង ស្រុក ខណ្ឌ................**
**ឃុំ សង្កាត់ ......................**

**គំរូតារាងបញ្ហា និងដំណោះស្រាយសម្រាប់គម្រោងសកម្មភាពអប់រំឪពុកម្តាយ អាណាព្យាបាល ឆ្នាំ២០....**

| បញ្ហា | ទីតាំងនៃបញ្ហា | មូលហេតុនៃបញ្ហា | តម្រូវការ | ដំណោះស្រាយ | ផ្សេងៗ |
|---|---|---|---|---|---|
| មានគ្រួសារដែលមានកុមារអាយុក្រោម៦ឆ្នាំមិនបានទទួលគម្រោងសកម្មភាពអប់រំឪពុកម្តាយ អាណាព្យាបាល ក្រុមបុរសជាឪពុកពុំសូវបានចូលរួមក្នុងវគ្គបណ្តុះបណ្តាល | | • មិនបានរៀបចំចងក្រងឪពុកម្តាយបង្គោល<br>• ក្រុមបុរសជាឪពុកជាប់រវល់ក្នុងការប្រមូលផលកសិកម្ម<br>• បុរសមួយចំនួននៅមិនទាន់យល់ដឹងអំពីសារៈសំខាន់នៃការគាំពារ និងអភិវឌ្ឍន៍កុមារតូច | • ចងក្រងឪពុកម្តាយបង្គោល ដើម្បីផ្តល់ការអប់រំប្រកប ដោយគុណភាព | • ចេញសេចក្តីសម្រេចបង្កើតឪពុកម្តាយ បង្គោល<br>• បណ្តុះបណ្តាល និងបំប៉ននូវគម្រោង សកម្មភាពអប់រំឪពុកម្តាយអាណាព្យាបាលក្នុងការគាំពារ និងអភិវឌ្ឍន៍កុមារតូចអាយុក្រោម៦ឆ្នាំ<br>• ផ្សព្វផ្សាយការអប់រំឪពុកម្តាយអាណាព្យាបាល<br>• ផ្តល់សម្ភារឯកសារបង្រៀន និងរៀន ដែល ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំ | |

| | | | | | |
|---|---|---|---|---|---|
| | | | • ក្រុមបុរសជាឪពុកទទួលបានគម្រោងសកម្មភាពអប់រំឪពុកម្តាយ អាណាព្យាបាលក្នុងការគាំពារ និងអភិវឌ្ឍន៍កុមារតូចអាយុក្រោម៦ឆ្នាំ ប្រកបដោយគុណភាព | • កំណត់ពេលវេលា កាលបរិច្ឆេទសមស្រប ដើម្បីកុំឱ្យប៉ះពាល់ដល់មុខរបរ ការងាររបស់ក្រុមបុរសជាឪពុក<br>• ចងក្រងក្រុមបុរសជាឪពុក<br>• បណ្តុះបណ្តាលទៅតាមគម្រោងសកម្មភាពអប់រំ ដែលក្រសួងអប់រំ យុវជន និងកីឡាបានចេញដាក់ឱ្យប្រើប្រាស់<br>• ផ្តល់សម្ភារបង្រៀន និងរៀនក្រុមបុរសជាឪពុក | |

ថ្ងៃ..........................ខែ...................ឆ្នាំ..............ព.ស............

ថ្ងៃទី...........ខែ..............ឆ្នាំ..............

**អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់**

ទម្រង់ទី៣

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជធានី ខេត្ត...................**

**ក្រុង ស្រុក ខណ្ឌ................**

**ឃុំ សង្កាត់ .....................**

**គំរូតម្រូវការសកម្មភាពអាទិភាពនៃគម្រោងសកម្មភាពរបស់ឪពុកម្តាយ អាណាព្យាបាលក្នុងការគាំពារ និងអភិវឌ្ឍន៍កុមារតូចអាយុក្រោម៦ឆ្នាំ ប្រចាំឆ្នាំ២០..**

| ល.រ | ឈ្មោះសកម្មភាព | ទីតាំង | លទ្ធផល | | រយៈពេល | អ្នកទទួលផល | | តម្លៃប៉ាន់ស្មាន (រៀល) | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | ឯកតា | បរិមាណ | | សរុប | ស្រី | | |
| ១ | ចងក្រងក្រុមឪពុកម្តាយ អាណាព្យាបាល | ភូមិ............... | ក្រុម | ៣ | ១២ខែ | ៦០ | ៤៥ | ០០ | |
| ២ | ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការអប់រំឪពុកម្តាយ អាណាព្យាបាល | ភូមិ................ | ក្រុម | ១ | ១២ខែ | ២០ | ១៥ | ៤៨០.០០០ | |
| ៣ | ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការអប់រំឪពុកម្តាយ អាណាព្យាបាល | ភូមិ............... | ក្រុម | ២ | ១២ខែ | ៤០ | ៣០ | ៩៦.០០០០ | |
| ៤ | ផ្តល់សម្ភារ ឯកសារ បង្រៀន និងរៀន | ភូមិ............... | ក្រុម | ៣ | ១២ខែ | ៦០ | ៤៥ | ............... | |

ថ្ងៃ........................ខែ..................ឆ្នាំ.............ព.ស...........

ថ្ងៃទី..........ខែ.............ឆ្នាំ.............

**អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់**

## ១.២. ការរៀបចំផែនការសកម្មភាព និងថវិកា

បន្ទាប់ពីសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ក្រុង ស្រុក ខណ្ឌរួច មេឃុំ ចៅសង្កាត់ត្រូវពិនិត្យមើលគម្រោងសកម្មភាពអប់រំ ឪពុកម្តាយ អាណាព្យាបាលដែលមិនមានអ្នកគាំទ្រ រួចពិចារណាពីលទ្ធភាពក្នុងការវិភាជន៍មូលនិធិឃុំ សង្កាត់ និងការកៀរគរធនធានពីសហគមន៍ក្នុងមូលដ្ឋានរបស់ខ្លួន សម្រាប់គាំទ្រគម្រោងសកម្មភាពសម្រាប់ឪពុកម្តាយ អាណាព្យាបាលតាមភូមិក្នុងឃុំ សង្កាត់របស់ខ្លួន។ ប្រសិនបើឃុំ សង្កាត់បានដាក់ថវិកាគាំទ្ររួចហើយតែមានការគាំទ្រពីដៃគូឃុំ សង្កាត់អាចដកថវិការបស់ខ្លួនទៅធ្វើសកម្មភាពផ្សេងដែលជាសកម្មភាពសង្គម ហើយផ្តល់ផលប្រយោជន៍ដល់ឃុំ សង្កាត់របស់ខ្លួន។ ការរៀបចំគម្រោងថវិកាឃុំ សង្កាត់ត្រូវអនុវត្តតាមនីតិវិធីដូចមានចែងនៅក្នុងសៀវភៅណែនាំស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់។ ការពិនិត្យឡើងវិញនេះត្រូវអនុវត្តតាមសកម្មភាពដូចខាងក្រោម៖

- គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ពិនិត្យមើលឡើងវិញអំពីគម្រោងសេវាសង្គម រួមទាំងគម្រោងអប់រំឪពុកម្តាយស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូចដែលមានអាយុក្រោម៦ឆ្នាំ ដើម្បីរៀបចំផែនការសកម្មភាព និងថវិកាសម្រាប់ដាក់បញ្ចូលទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់។ ក្នុងករណីគម្រោងសកម្មភាពអប់រំឪពុកម្តាយ អាណាព្យាបាលបានដាក់ក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំ សង្កាត់ ហើយឃុំ សង្កាត់មិនបានគ្រោងថវិកាមូលនិធិឃុំ សង្កាត់សម្រាប់ការប្រើប្រាស់លើគម្រោងទាំងនេះទេ និងក្រោយសមាហរណកម្មមិនមានអ្នកគាំទ្រទេ ឃុំ សង្កាត់អាចពិចារណាយកថវិកាពីគម្រោងដែលមានអ្នកគាំទ្រ មកគាំទ្រគម្រោងសកម្មភាពអប់រំ ឪពុកម្តាយអាណាព្យាបាល ស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូចនេះវិញ។
- មេឃុំ ចៅសង្កាត់ ត្រូវរាយការណ៍អំពីគម្រោងសកម្មភាពអប់រំឪពុកម្តាយ អាណាព្យាបាល ដល់ក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់។ (ទម្រង់ទី៤៖ គំរូផែនការសកម្មភាពនៃគម្រោងសកម្មភាពអប់រំឪពុកម្តាយ អាណាព្យាបាលស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូចក្រោមអាយុក្រោម៦ឆ្នាំ)។
- អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ត្រូវផ្សព្វផ្សាយគម្រោងសកម្មភាពអប់រំឪពុកម្តាយអាណាព្យាបាល ដល់គ.ក.ន.ក.។
- ប្រធានគណៈកម្មាធិការគ្រប់គ្រងគម្រោងសកម្មភាពអប់រំឪពុកម្តាយ អាណាព្យាបាល និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ត្រូវរៀបចំរបៀបវារៈកិច្ចប្រជុំផ្សព្វផ្សាយជាមួយប្រជាពលរដ្ឋ ឬសប្បុរសជននៅតាមភូមិនីមួយៗដើម្បីកៀរគរធនធាន និងថវិកាសម្រាប់ដំណើរការគម្រោងសកម្មភាពអប់រំឪពុកម្តាយអាណាព្យាបាលស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូចអាយុក្រោម៦ឆ្នាំក្នុងសហគមន៍របស់ខ្លួន (ទម្រង់ទី៥៖ គំរូផែនការថវិកាគម្រោងសកម្មភាពអប់រំឪពុកម្តាយ អាណា ព្យាបាលស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូចអាយុក្រោម៦ឆ្នាំ)។

ទម្រង់ទី៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត...................

ក្រុង ស្រុក ខណ្ឌ................

ឃុំ សង្កាត់ ......................

គំរូតម្រូវការសកម្មភាពអាទិភាពនៃគម្រោងសកម្មភាពអប់រំឪពុកម្តាយ អាណាព្យាបាលក្នុងការគាំពារ និងអភិវឌ្ឍន៍កុមារតូចអាយុក្រោម៦ឆ្នាំ ប្រចាំឆ្នាំ២០..

| ល.រ | សកម្មភាព | លទ្ធផលគ្រោង | | ទីតាំង | អ្នកទទួលផលផ្ទាល់ | | ខែ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ឯកតា | ចំនួន | | សរុប | ស្រី | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ១ | បង្កើតក្រុមឪពុកម្តាយបង្គោល | ក្រុម | ១ | ភូមិ........... | | | √ | | | | | | | | | | | |
| ២ | ផ្តល់វគ្គបណ្តុះបណ្តាល | វគ្គ | ១២ | ភូមិ........... | ២០ | ១៥ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| ៣ | ផ្តល់តង់កៅស៊ូក្រាលសម្រាប់អង្គុយ | តង់ | ១ | ភូមិ........... | ២០ | ១៥ | √ | | | | | | | | | | | |
| ៤ | ផ្តល់ប្រាក់ឧបត្ថម្ភឪពុកម្តាយបង្គោល និងអ្នកសម្របសម្រួល | នាក់ | ៤ | ភូមិ........... | ៤ | ៣ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |

ថ្ងៃ.........................ខែ..................ឆ្នាំ..............ព.ស............

ថ្ងៃទី..........ខែ.............ឆ្នាំ.............

**អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់**

ថ្ងៃ...........................ខែ..................ឆ្នាំ..............ព.ស..............

ថ្ងៃទី...............ខែ...........ឆ្នាំ..............

**មេឃុំ ចៅសង្កាត់**

ទម្រង់ទី៥

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជធានី ខេត្ត...................**
**ក្រុង ស្រុក ខណ្ឌ................**
**ឃុំ សង្កាត់ ......................**

**ផែនការថវិការបស់គម្រោងសកម្មភាពអប់រំឪពុកម្តាយ អាណាព្យាបាលស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូចអាយុក្រោម៦ឆ្នាំ ប្រចាំឆ្នាំ២០....**

| ល.រ | មុខចំណាយ | ឯកតា | ចំនួន | តម្លៃឯកតា(៛) | តម្លៃសរុប(៛) | មាតិកាចំណាយ | ប្រភពថវិកា |
|---|---|---|---|---|---|---|---|
| ១ | ការចងក្រុមឪពុកម្តាយ អាណាព្យាបាល | | | | | | |
| ១.១ | អាហារសម្រន់វគ្គបណ្តុះបណ្តាលឪពុកម្តាយ អាណាព្យាបាលប្រចាំខែ | ក្រុម | ១ | ៤០.០០០ | ៤០.០០០ | ៦១០៤១ | មូលនិធិឃុំ |
| | សរុប | | | | ៤០.០០០ | | |
| ២ | ការផ្តល់ប្រាក់ឧបត្ថម្ភដល់ឪពុកម្តាយបង្គោល និងអ្នកសម្របសម្រួល | | | | | | |
| ២.២ | ប្រាក់ឧបត្ថម្ភដល់ឪពុកម្តាយបង្គោល និង អ្នកសម្របសម្រួល | នាក់ | ៤ | ២០.០០០ | ៨០.០០០ | ៦១០៩៣ | មូលនិធិឃុំ |
| | សរុប | | | | ៨០.០០០ | | |
| ៣ | សម្ភារសម្រាប់បង្រៀន និងរៀន | | | | | | |
| ៣.២ | ក្រដាសពណ៌ | រាម | ៥ | ១២.០០០ | ៦០.០០០ | ៦២០៣១ | មូលនិធិឃុំ |
| ៣.៣ | តង់កៅស៊ូក្រាលសម្រាប់អង្គុយ | តង់ | ១ | ១០០.០០០ | ១០០.០០០ | ៦២០៣១ | មូលនិធិឃុំ |

| ល.រ | មុខចំណាយ | ការបរិយាយ | | | | កំណត់សម្គាល់ | |
|---|---|---|---|---|---|---|---|
| | | ឯកតា | ចំនួន | តម្លៃឯកតា(៛) | តម្លៃសរុប(៛) | មាតិកាចំណាយ | ប្រភពថវិកា |
| សរុប | | | | | ១៦០.០០០ | | |
| សរុបរួម | | | | | ២៨០.០០០ | | |

ថ្ងៃ..........................ខែ..................ឆ្នាំ..............ព.ស...........

ថ្ងៃទី...........ខែ..............ឆ្នាំ..............

**អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់**

ថ្ងៃ............................ខែ..................ឆ្នាំ...............ព.ស...............

ថ្ងៃទី...............ខែ............ឆ្នាំ..............

**មេឃុំ ចៅសង្កាត់**

# ជំពូកទី២

# ដំណើរការនៃការអប់រំ
# ឪពុកម្តាយ អាណាព្យាបាល




រូបភាព ការប្រជុំប្រចាំខែរបស់ក្រុមឪពុកម្ដាយ អាណាព្យាបាលនៅភូមិកោះស្រឡៅ ឃុំកោះស្នែង
ស្រុកបូរីសែនជ័យខេត្តស្ទឹងត្រែង

# ជំពូកទី២
# ដំណើរការនៃការអប់រំឪពុកម្តាយ អាណាព្យាបាល

ក្នុងដំណើរការនៃអប់រំឪពុកម្តាយ អាណាព្យាបាល រដ្ឋបាលឃុំ សង្កាត់ ត្រូវបង្កើតគណៈកម្មការគ្រប់គ្រង គម្រោងសកម្មភាពអប់រំឪពុកម្តាយ អាណាព្យាបាល នៅថ្នាក់ឃុំ សង្កាត់។ បន្ទាប់មក គណៈកម្មការគ្រប់គ្រង គម្រោងសកម្មភាពអប់រំឪពុកម្តាយ អាណាព្យាបាលឃុំ សង្កាត់ ត្រូវចងក្រងក្រុមឪពុកម្តាយ អាណាព្យាបាល ដែលមានកូនអាយុក្រោម៦ឆ្នាំ ដោយមានសមាជិកពី១៥ ទៅ២០នាក់ក្នុង១ក្រុម ហើយក្នុង១ភូមិអាចមាន ក្រុមឪពុកម្តាយ អាណាព្យាបាល២ ទៅ៣ក្រុម អាស្រ័យទៅតាមចំនួនឪពុកម្តាយដែលមានកូនអាយុក្រោម៦ឆ្នាំ ជាក់ស្តែង។ នៅក្នុងភូមិនីមួយៗ ត្រូវមានឪពុកម្តាយបង្គោល១នាក់ និងអ្នកសម្របសម្រួល២ ទៅ៣នាក់ អាស្រ័យលើចំនួនក្រុមក្នុងភូមិនីមួយៗដូចដ្យាក្រាមខាងក្រោម។



## ២.១. ការបង្កើតគណៈកម្មការគ្រប់គ្រងគម្រោងសកម្មភាពអប់រំឪពុកម្ដាយ អាណាព្យាបាល

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបង្កើតគណៈកម្មការគ្រប់គ្រងគម្រោងសកម្មភាពអប់រំឪពុកម្ដាយ អាណាព្យាបាល ដើម្បីជួយគ្រប់គ្រងគម្រោងសកម្មភាពអប់រំឪពុកម្ដាយ អាណាព្យាបាល ក្នុងការគាំពារ និងអភិវឌ្ឍន៍កុមារតូចអាយុក្រោម៦ឆ្នាំដល់ឃុំ សង្កាត់។

គណៈកម្មការគ្រប់គ្រងគម្រោងសកម្មភាពអប់រំឪពុកម្ដាយអាណាព្យាបាលត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់មេឃុំ ចៅសង្កាត់ និងមានគណនេយ្យភាពជាមួយឃុំ សង្កាត់។

គណៈកម្មការគ្រប់គ្រងគម្រោងសកម្មភាពអប់រំឪពុកម្ដាយ អាណាព្យាបាល ក្នុងការគាំពារ និងអភិវឌ្ឍន៍កុមារតូចអាយុក្រោម៦ឆ្នាំ ត្រូវមានសមាជិកយ៉ាងច្រើន៧រូប រួមមាន៖

- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់១រូប ជាប្រធាន
- អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ជាអនុប្រធាន
- តំណាងសាលាបឋមសិក្សា១រូប ជាសមាជិក
- មេភូមិ ឬអនុប្រធានភូមិ១រូប ជាសមាជិក
- តំណាងឪពុកម្ដាយ អាណាព្យាបាល១រូប ជាសមាជិក
- តំណាងមណ្ឌលសុខភាព១រូប ជាសមាជិក
- តំណាងអ្នកស្ម័គ្រចិត្តភូមិ១រូប ជាសមាជិក

តំណាងឪពុកម្ដាយ អាណាព្យាបាលកុមារ គឺជាសមាជិកនៃក្រុមឪពុកម្ដាយ អាណាព្យាបាលកុមារ (ឪពុកម្ដាយដែលមានកូនអាយុក្រោម៦ឆ្នាំ) ម្នាក់ក្នុងចំណោមក្រុមឪពុកម្ដាយ អាណាព្យាបាលដែលមានប្រជាប្រិយភាពក្នុងភូមិ។

តំណាងអ្នកស្ម័គ្រចិត្តភូមិ គឺជាអ្នកដែលមានបទពិសោធន៍ និងការយល់ដឹងស្ដីពីកុមារតូច ឬទទួលបានវគ្គបណ្ដុះបណ្ដាលស្ដីអំពីការអប់រំកុមារតូច។

បន្ទាប់ពីជ្រើសរើសបានសមាសភាពគណៈកម្មការរួច មេឃុំ ចៅសង្កាត់ ត្រូវរៀបចំសេចក្ដីព្រាងសេចក្ដីសម្រេចស្ដីពីការបង្កើតគណៈកម្មការគ្រប់គ្រងគម្រោងសកម្មភាពអប់រំឪពុកម្ដាយ អាណាព្យាបាល ដើម្បីដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ ពិនិត្យ និងអនុម័ត (ទម្រង់ទី៦៖ គំរូសេចក្ដីសម្រេចស្ដីពីការបង្កើតគណៈកម្មការគ្រប់គ្រងគម្រោងសកម្មភាពអប់រំឪពុកម្ដាយ អាណាព្យាបាលឃុំ សង្កាត់)។

គណៈកម្មការគ្រប់គ្រងគម្រោងសកម្មភាពអប់រំឪពុកម្ដាយ អាណាព្យាបាលមានភារកិច្ចដូចខាងក្រោម៖

- ចូលរួមរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល
- រៀបចំផែនការគម្រោងសកម្មភាពអប់រំឪពុកម្ដាយ អាណាព្យាបាល
- ជ្រើសរើស និងវាយតម្លៃឪពុកម្ដាយបង្គោល
- រៀបចំកិច្ចប្រជុំប្រចាំខែរបស់គណៈកម្មការ ដោយមានការរៀបចំកំណត់ហេតុប្រជុំ

- កៀរគរធនធាន និងថវិកាពីសហគមន៍ក្នុងមូលដ្ឋាន និងសប្បុរសជន
- ផ្សព្វផ្សាយ និងជំរុញការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការគ្រប់គ្រងគម្រោងសកម្មភាពអប់រំឪពុកម្តាយ អាណាព្យាបាល
- រៀបចំដំណើរការគ្រប់គ្រងគម្រោងសកម្មភាពអប់រំឪពុកម្តាយ អាណាព្យាបាល
- តាមដានជាប្រចាំ និងរាយការណ៍អំពីដំណើរការគ្រប់គ្រងគម្រោងសកម្មភាពអប់រំឪពុកម្តាយ អាណា-ព្យាបាលជូនមេឃុំ ចៅសង្កាត់
- រៀបចំប្រជុំជាមួយឪពុកម្តាយ អាណាព្យាបាលកុមារ ដើម្បីឆ្លុះបញ្ចាំងអំពីការប្រែប្រួលឥរិយាបថរបស់ឪពុកម្តាយ
- ប្រមូលទិន្នន័យសម្រាប់គម្រោងសកម្មភាពអប់រំឪពុកម្តាយ អាណាព្យាបាល
- រៀបចំ និងគ្រប់គ្រងសម្ភារសម្រាប់ដំណើរការគ្រប់គ្រងគម្រោងសកម្មភាព
- រៀបចំទីកន្លែងជួបជុំ ដែលមានបរិស្ថានប្រកបដោយសុវត្ថិភាព។

ទម្រង់ទី៦

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជធានី ខេត្ត....................**

**ក្រុង ស្រុក ខណ្ឌ................**

**ឃុំ សង្កាត់ ......................**

**សេចក្ដីសម្រេច**
**ស្ដីពី**
**ការបង្កើតគណៈកម្មការគ្រប់គ្រងគម្រោងសកម្មភាពអប់រំឪពុកម្ដាយ អាណាព្យាបាលឃុំ សង្កាត់**

- យោងព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងអនុក្រឹត្យលេខ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្ដីពីការផ្ទេរមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់
- យោងប្រកាសលេខ៣៨៤០ ប្រក ចុះថ្ងៃអង្គារ ៥កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់
- យោងតាមស្មារតីនៃអង្គប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ លើកទី......... អាណត្តិទី.......... នាថ្ងៃទី....... ខែ....... ឆ្នាំ...........

**សម្រេច**

**ប្រការ១.-**

ត្រូវបានបង្កើតគណៈកម្មការគ្រប់គ្រងគម្រោងសកម្មភាពអប់រំឪពុកម្ដាយ អាណាព្យាបាលឃុំ សង្កាត់ ដែលមានសមាសភាពដូចខាងក្រោម៖

- លោក លោកស្រី សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ជាប្រធាន
- លោក លោកស្រី អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ជាអនុប្រធាន
- លោក លោកស្រី តំណាងសាលាបឋមសិក្សា១រូប ជាសមាជិក
- លោក លោកស្រី មេភូមិ ឬ អនុប្រធានភូមិ១រូប ជាសមាជិក
- លោក លោកស្រី តំណាងឪពុកម្ដាយ អាណាព្យាបាល១រូប ជាសមាជិក
- លោក លោកស្រី តំណាងមណ្ឌលសុខភាពឃុំ១រូប ជាសមាជិក
- លោក លោកស្រី តំណាងអ្នកស្ម័គ្រចិត្តភូមិ១រូប ជាសមាជិក

**ប្រការ២.-**

គណៈកម្មការគ្រប់គ្រងគម្រោងសកម្មភាពអប់រំឪពុកម្ដាយមានភារកិច្ចដូចខាងក្រោម៖

- ចូលរួមរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល
- រៀបចំផែនការគម្រោងសកម្មភាពអប់រំឪពុកម្ដាយ អាណាព្យាបាល

- ជ្រើសរើស និងវាយតម្លៃឪពុកម្តាយបង្គោល
- រៀបចំកិច្ចប្រជុំប្រចាំខែរបស់គណៈកម្មការ ដោយមានការរៀបចំកំណត់ហេតុប្រជុំ
- កៀរគរធនធាន និងថវិកាពីសហគមន៍ក្នុងមូលដ្ឋាន និងសប្បុរសជន
- ផ្សព្វផ្សាយ និងជំរុញការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការគ្រប់គ្រងគម្រោងសកម្មភាពអប់រំឪពុកម្តាយ អាណាព្យាបាល
- រៀបចំដំណើរការគ្រប់គ្រងគម្រោងសកម្មភាពអប់រំឪពុកម្តាយ អាណាព្យាបាល
- តាមដានជាប្រចាំ និងរាយការណ៍អំពីដំណើរការគ្រប់គ្រងគម្រោងសកម្មភាពអប់រំឪពុកម្តាយ អាណាព្យាបាលជូនមេឃុំ ចៅសង្កាត់
- រៀបចំប្រជុំជាមួយឪពុកម្តាយ អាណាព្យាបាលកុមារ ដើម្បីឆ្លុះបញ្ចាំងអំពីការប្រែប្រួលឥរិយាបថរបស់ឪពុកម្តាយ
- ប្រមូលទិន្នន័យសម្រាប់គម្រោងសកម្មភាពអប់រំឪពុកម្តាយ អាណាព្យាបាល
- រៀបចំ និងគ្រប់គ្រងសម្ភារសម្រាប់ដំណើរការគ្រប់គ្រងគម្រោងសកម្មភាព
- រៀបចំទីកន្លែងជួបជុំដែលមានបរិស្ថានប្រកបដោយសុវត្ថិភាព
- បំពេញភារកិច្ចផ្សេងៗទៀតតាមការចាំបាច់។

**ប្រការ៣.-**

គណៈកម្មការគ្រប់គ្រងគម្រោងសកម្មភាពអប់រំឪពុកម្តាយ អាណាព្យាបាលត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់មេឃុំ ចៅសង្កាត់ និងមានគណនេយ្យភាពចំពោះក្រុមប្រឹក្សាឃុំ សង្កាត់។

**ប្រការ៤.-**

គណៈកម្មការគ្រប់គ្រងគម្រោងសកម្មភាពអប់រំឪពុកម្តាយ អាណាព្យាបាលត្រូវរៀបចំកិច្ចប្រជុំប្រចាំខែរបស់ខ្លួនក្រោមការដឹកនាំរបស់ប្រធានគណៈកម្មការ។ ក្នុងករណីអវត្តមានប្រធានត្រូវផ្ទេរសិទ្ធិទៅអនុប្រធានដើម្បីដឹកនាំកិច្ចប្រជុំ។

ប្រធានគណៈកម្មការគ្រប់គ្រងគម្រោងសកម្មភាពអប់រំឪពុកម្តាយ អាណាព្យាបាលអាចអញ្ជើញអ្នកពាក់ព័ន្ធចូលរួមក្នុងកិច្ចប្រជុំតាមការចាំបាច់។

**ប្រការ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៦.-**

គ្រប់សមាសភាពដែលមានចែងក្នុងប្រការ១ និងអ្នកពាក់ព័ន្ធត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធ- ភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ.................ខែ............ឆ្នាំ............ព.ស.........

ថ្ងៃទី.........ខែ............ឆ្នាំ.........

**មេឃុំ ចៅសង្កាត់**

**ចម្លងជូន៖**

- រដ្ឋបាលរាជធានី ខេត្ត
- រដ្ឋបាលក្រុង ស្រុក ខណ្ឌ
  "ដើម្បីជូនជ្រាប"
- សាមីខ្លួន
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

## ២.២. ការជ្រើសរើសឪពុកម្តាយបង្គោល

គណៈកម្មការគ្រប់គ្រងគម្រោងសកម្មភាពអប់រំឪពុកម្តាយ អាណាព្យាបាល ត្រូវជ្រើសរើសអ្នកស្ម័គ្រចិត្តធ្វើជាឪពុកម្តាយបង្គោល១នាក់ក្នុង១ភូមិ ដើម្បីធ្វើជាគ្រូបង្គោលក្នុងការអប់រំឪពុកម្តាយ អាណាព្យាបាលក្នុងការគាំពារ និងអភិវឌ្ឍន៍កុមារតូចអាយុក្រោម៦ឆ្នាំ។

ឪពុកម្តាយបង្គោលអាចជាឪពុកម្តាយ អាណាព្យាបាលក្នុងភូមិដែលមានចំណេះដឹង និងបទពិសោធន៍លើការថែទាំសុខភាព អនាម័យ និងការចិញ្ចឹមកូនបែបវិជ្ជមាន។ ឪពុកម្តាយបង្គោលគួរមានបទពិសោធន៍ជាអ្នកសម្របសម្រួល បង្វឹក និងបណ្តុះបណ្តាលដែលមានអាយុពី៣៥ឆ្នាំ ទៅ៤៥ឆ្នាំ និងមានកម្រិតវប្បធម៌យ៉ាងតិចចេះអាន និងចេះសរសេរ។ ឪពុកម្តាយបង្គោលអាចជាលោកគ្រូ អ្នកគ្រូមត្តេយ្យសហគមន៍ ឬមេភូមិ ឬអនុភូមិដែលមានចំណេះដឹងលើចិត្តសាស្ត្រកុមារ និងការអភិវឌ្ឍកុមារតូច។

ឪពុកម្តាយបង្គោលមានភារកិច្ចដូចខាងក្រោម៖

- ចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗដែលពាក់ព័ន្ធកិច្ចគាំពារ និងអភិវឌ្ឍន៍កុមារតូច
- រៀបចំបញ្ជីឈ្មោះឪពុកម្តាយ អាណាព្យាបាល
- ចងក្រងក្រុមឪពុកម្តាយ អាណាព្យាបាល
- ជ្រើសរើសអ្នកសម្របសម្រួល១នាក់ក្នុង១ក្រុម
- រៀបចំផែនការបណ្តុះបណ្តាល និងសម្ភារឧបទ្ទេស
- ធ្វើការបណ្តុះបណ្តាល និងផ្សព្វផ្សាយស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច
- ធ្វើរបាយការណ៍វគ្គបណ្តុះបណ្តាលជូនទៅគណៈកម្មការគ្រប់គ្រងគម្រោង
- រៀបចំផែនការបណ្តុះបណ្តាល បំប៉នប្រចាំខែទៅក្រុមឪពុកម្តាយ អាណាព្យាបាល និងរៀបចំសម្ភារឧបទ្ទេស
- ធ្វើការបណ្តុះបណ្តាល បំប៉នប្រចាំខែ និងផ្សព្វផ្សាយស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការបណ្តុះបណ្តាលជូនទៅគណៈកម្មការគ្រប់គ្រងគម្រោង
- លើកទឹកចិត្តបុរសឱ្យចូលរួមកាន់តែច្រើន និងសកម្មក្នុងការងារគាំពារ និងអភិវឌ្ឍន៍កុមារតូច។

ឪពុកម្តាយបង្គោលតាមភូមិនីមួយៗត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់តាមរយៈកិច្ចប្រជុំក្រុមប្រឹក្សា។ (ទម្រង់ទី៧៖ គំរូសេចក្តីសម្រេចស្តីពីការតែងតាំងឪពុកម្តាយបង្គោល)

ឪពុកម្តាយបង្គោលនឹងទទួលបានប្រាក់ឧបត្ថម្ភ សម្រាប់ការអនុវត្តសកម្មភាពដោយផ្អែកតាមមាតិកាចំណាយដែលមានក្នុងគម្រោងថវិកាប្រចាំឆ្នាំឃុំ សង្កាត់ (អនុគណនី៦១០៩៣)។

ទម្រង់ទី៧

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត...................

ក្រុង ស្រុក ខណ្ឌ................

ឃុំ សង្កាត់ .....................

**សេចក្តីសម្រេច**

**ស្តីពី**

**ការតែងតាំងឪពុកម្តាយបង្កោល**

- យោងព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងអនុក្រឹត្យលេខ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់
- យោងប្រកាសលេខ៣៨៤០ ប្រក ចុះថ្ងៃអង្គារ ៥កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់
- យោងតាមស្មារតីនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ លើកទី........អាណត្តិទី.........នាថ្ងៃទី.......... ខែ........ ឆ្នាំ.......

**សម្រេច**

**ប្រការ១.-**

ត្រូវបានតែងតាំងឪពុកម្តាយបង្កោល ចំនួន.......រូប ដូចមានរាយនាមខាងក្រោម៖

- លោក លោកស្រី...........................ជាឪពុកម្តាយបង្កោលក្នុងភូមិ..................
- លោក លោកស្រី...........................ជាឪពុកម្តាយបង្កោលក្នុងភូមិ..................
- លោក លោកស្រី...........................ជាឪពុកម្តាយបង្កោលក្នុងភូមិ..................
- លោក លោកស្រី...........................ជាឪពុកម្តាយបង្កោលក្នុងភូមិ..................
- លោក លោកស្រី...........................ជាឪពុកម្តាយបង្កោលក្នុងភូមិ..................
- លោក លោកស្រី...........................ជាឪពុកម្តាយបង្កោលក្នុងភូមិ..................
- ........................................................................................................

**ប្រការ២.-**

ឪពុកម្ដាយបង្គោលមានភារកិច្ចដូចខាងក្រោម៖

- ចូលរួមវគ្គបណ្ដុះបណ្ដាលផ្សេងៗដែលពាក់ព័ន្ធកិច្ចគាំពារ និងអភិវឌ្ឍន៍កុមារតូច
- រៀបចំបញ្ជីឈ្មោះឪពុកម្ដាយ អាណាព្យាបាល
- ចងក្រងក្រុមឪពុកម្ដាយ អាណាព្យាបាល
- ជ្រើសរើសអ្នកសម្របសម្រួល១នាក់ក្នុង១ក្រុម
- រៀបចំផែនការបណ្ដុះបណ្ដាល និងសម្ភារឧបទ្ទេស
- ធ្វើការបណ្ដុះបណ្ដាល និងផ្សព្វផ្សាយស្ដីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច
- ធ្វើរបាយការណ៍វគ្គបណ្ដុះបណ្ដាលជូនទៅគណៈកម្មការគ្រប់គ្រងគម្រោង។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

សេចក្ដីសម្រេចនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ..................ខែ.............ឆ្នាំ.............ព.ស..........

ថ្ងៃទី..........ខែ.............ឆ្នាំ.........

**មេឃុំ ចៅសង្កាត់**

**ចម្លងជូន៖**

- រដ្ឋបាលរាជធានី ខេត្ត
- រដ្ឋបាលក្រុង ស្រុក ខណ្ឌ
  "ដើម្បីជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ

## ២.៣. ការជ្រើសរើសអ្នកសម្របសម្រួល

ឪពុកម្តាយបង្គោលត្រូវជ្រើសរើសអ្នកស្ម័គ្រចិត្តធ្វើជាអ្នកសម្របសម្រួល ១នាក់ក្នុង១ក្រុម រួចស្នើសុំទៅក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីអនុម័ត និងចេញសេចក្តីសម្រេចតែងតាំងអ្នកសម្របសម្រួលសកម្មភាពអប់រំក្រុមឪពុកម្តាយ អាណាព្យាបាលក្នុងការគាំពារ និងអភិវឌ្ឍន៍កុមារតូចអាយុក្រោម៦ឆ្នាំ (ទម្រង់ទី៧៖ យកលំនាំតាមទម្រង់ឪពុកម្តាយបង្គោល)។

អ្នកសម្របសម្រួលមានភារកិច្ចដូចខាងក្រោម៖

- ចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗដែលពាក់ព័ន្ធកិច្ចគាំពារ និងអភិវឌ្ឍន៍កុមារតូច
- ជួយឪពុកម្តាយបង្គោលក្នុងការរៀបចំបញ្ជីឈ្មោះឪពុកម្តាយ អាណាព្យាបាល
- ជួយឪពុកម្តាយបង្គោលក្នុងការចងក្រងក្រុមឪពុកម្តាយ អាណាព្យាបាល
- ជួយឪពុកម្តាយបង្គោលក្នុងការរៀបចំផែនការបណ្តុះបណ្តាល និងសម្ភារឧបទ្ទេស
- ជួយឪពុកម្តាយបង្គោលក្នុងការបណ្តុះបណ្តាល និងផ្សព្វផ្សាយស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច
- ជួយឪពុកម្តាយបង្គោលក្នុងការធ្វើរបាយការណ៍វគ្គបណ្តុះបណ្តាលជូនទៅគណៈកម្មការគ្រប់គ្រងគម្រោង។

អ្នកសម្របសម្រួលគួរជ្រើសរើសចេញពីបុគ្គលមួយចំនួនដូចខាងក្រោម៖

- ប្រធាន ឬអនុប្រធានភូមិ ដែលមានចំណេះដឹងអំពីការការពារកុមារក្នុងសហគមន៍
- លោកគ្រូ អ្នកគ្រូមត្តេយ្យសហគមន៍ដែលមានចំណេះដឹងច្រើនលើចិត្តសាស្ត្រកុមារ និងការអភិវឌ្ឍកុមារតូច
- ជនបង្គោល អនាម័យភូមិដែលមានចំណេះដឹងលើការថែទាំសុខភាព និងអនាម័យ
- អ្នកស្ម័គ្រចិត្តសុខភាពភូមិដែលមានចំណេះដឹងលើការថែទាំសុខភាព និងអនាម័យ
- ឪពុកម្តាយដែលមានប្រជាប្រិយភាពក្នុងភូមិ និងមានចំណេះដឹងអំពីការការពារកុមារក្នុងសហគមន៍។

អ្នកសម្របសម្រួលនឹងទទួលបានប្រាក់ឧបត្ថម្ភសម្រាប់ការអនុវត្តសកម្មភាពដោយផ្អែកតាមមាតិកាចំណាយដែលមានក្នុងគម្រោងថវិកាប្រចាំឆ្នាំឃុំ សង្កាត់ (អនុគណនី៦១០៩៣)។

## ២.៤. ការចងក្រងក្រុមឪពុកម្តាយ អាណាព្យាបាល

ដើម្បីឱ្យមានភាពងាយស្រួលក្នុងការគ្រប់គ្រងការរៀន និងបង្រៀនប្រចាំខែ ឪពុកម្តាយបង្គោលត្រូវចងក្រង ក្រុមឪពុកម្តាយ អាណាព្យាបាលដែលមានកូនអាយុក្រោម៦ឆ្នាំ ក្នុងភូមិរបស់ខ្លួន។ ក្រុមឪពុកម្តាយអាណាព្យាបាលត្រូវមានសមាជិកក្នុង១ក្រុមពី១៥ ទៅ ២០នាក់ ដែលមានចំនួនបុរស និងស្ត្រីប្រហាក់ប្រហែលគ្នា ហើយក្នុងមួយភូមិអាចមានច្រើនក្រុម អាស្រ័យទៅតាមចំនួនឪពុកម្តាយ អាណាព្យាបាលដែលមានកូនអាយុក្រោម៦ឆ្នាំជាក់ស្តែង។

ក្រុមឪពុកម្តាយ អាណាព្យាបាលមានតួនាទីដូចខាងក្រោម៖
- ចូលរួមសកម្មភាពអប់រំឪពុកម្តាយ អាណាព្យាបាល តាមកម្មវិធីដែលឪពុកម្តាយបង្គោលបានរៀបចំ
- យកចំណេះដឹងដែលបានរៀនសូត្រមកអនុវត្តជាប្រចាំ ដែលរួមមានការថែទាំសុខភាព អាហារូបត្ថម្ភ អប់រំកុមារតាំងពីវ័យដំបូង និងការពារសុវត្ថិភាពកុមារជៀសវាងការប្រើអំពើហិង្សា
- ធ្វើល្បែងងាយៗដោយប្រើសម្ភារដែលមានក្នុងមូលដ្ឋានឱ្យកូនលេង និងរៀបចំកន្លែងដែលមានសុវត្ថិភាពឱ្យកូនលេង
- សង្កេតតាមដានការរីកចម្រើនសុខភាព និងសមត្ថភាពរបស់កុមារ
- ចូលរួមចែករំលែកបទពិសោធន៍ និងការសិក្សារៀនសូត្រថ្មីៗក្នុងការគាំពារ និងអភិវឌ្ឍន៍កុមារតូច និងចិញ្ចឹមបីបាច់កូនតាមបែបវិជ្ជមាននៅក្នុងសហគមន៍ និងកម្មវិធីផ្សេងៗ ដែលរៀបចំដោយក្រសួង ស្ថាប័ន អង្គការដៃគូនានា។

## ២.៥. ការបណ្តុះបណ្តាលឪពុកម្តាយបង្គោល និងអ្នកសម្របសម្រួល

ដើម្បីធានាថា ឪពុកម្តាយបង្គោល និងអ្នកសម្របសម្រួលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបង្រៀនបន្តទៅឪពុកម្តាយ អាណាព្យាបាល គណៈកម្មការគ្រប់គ្រងគម្រោងសកម្មភាពអប់រំឪពុកម្តាយ អាណាព្យាបាលឃុំ សង្កាត់ត្រូវ៖

- កំណត់តម្រូវការអភិវឌ្ឍន៍សមត្ថភាព និងចំណុចកែលម្អ
- រៀបចំគម្រោងសកម្មភាពអភិវឌ្ឍន៍សមត្ថភាពឪពុកម្តាយបង្គោល និងអ្នកសម្របសម្រួល
- សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលរាជធានី ខេត្ត មន្ទីរជំនាញ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ការិយាល័យអប់រំ យុវជន និងកីឡា ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម មណ្ឌលសុខភាព អង្គការដៃគូ វិស័យឯកជន ដើម្បីឱ្យឪពុកម្តាយបង្គោល និងអ្នកសម្របសម្រួលទទួលបានការបណ្តុះបណ្តាលស្តីពីការអប់រំឪពុកម្តាយក្នុងការគាំពារ និងអភិវឌ្ឍន៍កុមារតូចអាយុក្រោម៦ឆ្នាំ សមស្របតាមតម្រូវការ
- សម្របសម្រួលឱ្យក្រុមឪពុកម្តាយបង្គោល និងអ្នកសម្របសម្រួលបានចូលរួមវគ្គបណ្តុះបណ្តាល វគ្គបំប៉ន ការប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ និងការប្រជុំបច្ចេកទេសប្រចាំខែតាមកាលវិភាគរបស់ការិយាល័យអប់រំយុវជន និងកីឡាក៏ដូចជាការិយាល័យសង្គមកិច្ច និងសុខមាលភាពសង្គម។



រូបភាព ការចុះជួយបង្រៀនបន្ថែមដល់ឪពុកម្តាយ អាណាព្យាបាលនៅតាមខ្នងផ្ទះក្នុងភូមិប្រស្នា ឃុំអង្គរាជ្យ ស្រុកព្រះស្តេច ខេត្តព្រៃវែង

# ជំពូកទី៣

# ការតាមដាន ត្រួតពិនិត្យ
# និងការរៀបចំរបាយការណ៍



រូបភាព ការប្រជុំរបស់ឪពុកម្ដាយបង្គោល អំពីវឌ្ឍនភាព និងការរៀបចំរបាយការណ៍ ភូមិណាយ ឃុំញ៉ាង
ស្រុកអណ្ដូងងមាស  ខេត្តរតនគិរី

# ជំពូកទី៣
# ការតាមដាន ត្រួតពិនិត្យ និងការរៀបចំរបាយការណ៍

ដើម្បីធានាថាគម្រោងសកម្មភាពអប់រំឪពុកម្ដាយ អាណាព្យាបាល ដំណើរការអនុវត្តបានល្អ និងប្រកបដោយប្រសិទ្ធភាព រដ្ឋបាលឃុំ សង្កាត់ត្រូវធ្វើការតាមដាន ត្រួតពិនិត្យ ដោយស្វែងរកចំណុចខ្លាំង បញ្ហាប្រឈម និងតម្រូវការជាក់ស្ដែងក្នុងការអនុវត្តគម្រោង។ ជាមួយគ្នានេះ ត្រូវមានការរៀបចំជារបាយការណ៍ស្ដីពីដំណើរការអនុវត្តគម្រោងតាមរបបកំណត់ជាប្រចាំ ដើម្បីដឹងពីភាពជោគជ័យ និងចំណុចដែលត្រូវកែលម្អ។

## ៣.១. ការតាមដាន ត្រួតពិនិត្យ

ការតាមដាន ត្រួតពិនិត្យត្រូវអនុវត្តតាមសកម្មភាពសំខាន់ៗដូចខាងក្រោម៖

- គណៈកម្មការគ្រប់គ្រងគម្រោងសកម្មភាពអប់រំឪពុកម្ដាយ អាណាព្យាបាលត្រូវចាត់តាំងសមាជិកណាម្នាក់ឱ្យចុះត្រួតពិនិត្យដោយផ្ទាល់អំពីការអនុវត្ត និងការគ្រប់គ្រងក្រុមឪពុកម្ដាយបង្គោល ដើម្បីគាំទ្រដល់ក្រុមឪពុកម្ដាយបង្គោល និងមានការកត់ត្រាឱ្យបានច្បាស់លាស់រាល់ការគាំទ្រនានា រួមទាំងចំណុចល្អៗ ដែលបានអនុវត្ត និងអ្វីដែលត្រូវអនុវត្តបន្តសម្រាប់ក្រុមនៅក្នុងការបណ្ដុះបណ្ដាលបន្ទាប់
- ប្រធានគណៈកម្មការគ្រប់គ្រងគម្រោងសកម្មភាពអប់រំឪពុកម្ដាយ អាណាព្យាបាលត្រូវជួបប្រជុំជាមួយសមាជិកដែលបានចាត់តាំងឱ្យចុះត្រួតពិនិត្យ និងតាមដានដើម្បីបូកសរុប និងរៀបចំរបាយការណ៍អំពីលទ្ធផលតាមដាន ត្រួតពិនិត្យជូនគណៈកម្មការគ្រប់គ្រងគម្រោងសកម្មភាពអប់រំឪពុកម្ដាយ អាណាព្យាបាលនៅក្នុងកិច្ចប្រជុំប្រចាំខែរបស់ខ្លួន ដើម្បីលើកឡើងនូវបញ្ហានានាដែលបានជួបប្រទះ និងស្វែងរកវិធានការដោះស្រាយ
- គណៈកម្មការគ្រប់គ្រងគម្រោងសកម្មភាពអប់រំឪពុកម្ដាយ អាណាព្យាបាលរាយការណ៍អំពីលទ្ធផលតាមដាន ត្រួតពិនិត្យជូនមេឃុំ ចៅសង្កាត់ ដើម្បីសុំការគាំទ្រ និងកែលម្អទៅថ្ងៃខាងមុខ។

## ៣.២. ការរៀបចំរបាយការណ៍

គណៈកម្មការគ្រប់គ្រងគម្រោងសកម្មភាពអប់រំឪពុកម្ដាយ អាណាព្យាបាលត្រូវទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ប្រចាំខែ និងប្រចាំឆ្នាំ ដើម្បីដាក់ជូនមេឃុំ ចៅសង្កាត់។ ក្រុមឪពុកម្ដាយបង្គោលត្រូវជួយគណៈកម្មការគ្រប់គ្រងគម្រោងសកម្មភាពអប់រំឪពុកម្ដាយ អាណាព្យាបាលបូកសរុបសកម្មភាពការងាររបស់ក្រុមរបស់ខ្លួន ដែលបានអនុវត្តកន្លងមក ដើម្បីរៀបចំរបាយការណ៍ប្រចាំខែ និងប្រចាំឆ្នាំ (ទម្រង់ទី៨៖ របាយ-ការណ៍ស្ដីពីការគ្រប់គ្រងដំណើរការអប់រំឪពុកម្ដាយ អាណាព្យាបាល)។

ទម្រង់ទី៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត....................
ក្រុង ស្រុក ខណ្ឌ................
ឃុំ សង្កាត់ ......................

របាយការណ៍ស្តីពីការគ្រប់គ្រងដំណើរការអប់រំឪពុកម្តាយ អាណាព្យាបាល នៅភូមិ.............. ប្រចាំខែ............ ឆ្នាំ២០..........

| ល.រ | សកម្មភាព | លទ្ធផល | | | ចំនួនអ្នកទទួលផល | | បញ្ហាប្រឈម | ដំណោះស្រាយ ឬអនុសាសន៍ |
|---|---|---|---|---|---|---|---|---|
| | | ឯកតា | គ្រោង | សម្រេចបាន | សរុប | ស្រី | | |
| ១ | **ការធ្វើផែនការ និងការតាមដានត្រួតពិនិត្យ** | | | | | | | |
| ១.១ | ផ្តល់វគ្គបណ្តុះបណ្តាល | វគ្គ | | | | | | |
| ១.២ | រៀបចំផែនការសកម្មភាពបង្រៀន តាមប្រធានបទ ឬមេរៀនទាក់ទងនិងការអប់រំថែទាំកុមារអាយុក្រោម៦ឆ្នាំ | ប្រធានបទ | | | | | | |
| ១.៣ | ចូលរួមប្រជុំបច្ចេកទេសរៀងរាល់ខែតាមគម្រោងសកម្មភាពរបស់ការិយាល័យជំនាញ និងអ្នកពាក់ព័ន្ធ | ប្រជុំ | | | | | | |
| ១.៤ | ស្វ័យវាយតម្លៃក្រុមឪពុកម្តាយបង្គោល | លើក | | | | | | |
| ១.៥ | វាយតម្លៃការអនុវត្តការងារក្រុមឪពុកម្តាយបង្គោល | លើក | | | | | | |
| ១.៦ | ចុះត្រួតពិនិត្យជាប្រចាំអំពីដំណើរការវគ្គបណ្តុះបណ្តាល | លើក | | | | | | |

| ល.រ | សកម្មភាព | លទ្ធផល | | | ចំនួនអ្នកទទួលផល | | បញ្ហាប្រឈម | ដំណោះស្រាយ ឬអនុសាសន៍ |
|---|---|---|---|---|---|---|---|---|
| | | ឯកតា | គ្រោង | សម្រេចបាន | សរុប | ស្រី | | |
| ១.៧ | ក្រុមប្រឹក្សាឃុំ សង្កាត់ចុះពិនិត្យការគ្រប់គ្រងគម្រោងសកម្មភាព | លើក | | | | | | |
| **២** | **ការរៀបចំវគ្គបណ្តុះបណ្តាល** | | | | | | | |
| ២.១ | យុទ្ធនាការចុះឈ្មោះ ឪពុកម្តាយ អាណាព្យាបាល | លើក | | | | | | |
| ២.២ | ការផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការអប់រំសម្រាប់ឪពុកម្តាយ អាណាព្យាបាល | ខែ | | | | | | |
| ២.៣ | ផលិត និងរកសម្ភារក្នុងមូលដ្ឋានសម្រាប់បង្រៀនឪពុកម្តាយ អាណាព្យាបាលឱ្យចេះផលិតសម្ភារល្បែងងាយៗឱ្យកូនលេង។ | សម្ភារ | | | | | | |
| ២.៤ | រៀបចំតុបតែងទីកន្លែងបណ្តុះបណ្តាល | លើក | | | | | | |
| ២.៥ | ធ្វើតេស្តទៀងទាត់ ដោយអនុវត្ត១ឆ្នាំ ២ដង ចំពោះឪពុកម្តាយ អាណាព្យាបាល | ដង | | | | | | |
| ២.៦ | រៀបចំ និងបញ្ជូនបញ្ជីឈ្មោះឪពុកម្តាយអាណាព្យាបាលទៅតាមក្រុមនីមួយៗ | លើក | | | | | | |

| ល.រ | សកម្មភាព | លទ្ធផល | | | ចំនួនអ្នកទទួលផល | | បញ្ហាប្រឈម | ដំណោះស្រាយ ឬអនុសាសន៍ |
|---|---|---|---|---|---|---|---|---|
| | | ឯកតា | គ្រោង | សម្រេចបាន | សរុប | ស្រី | | |
| **៣** | **ការគ្រប់គ្រងទូទៅ** | | | | | | | |
| ៣.១ | ចូលរួមវគ្គបណ្តុះបណ្តាលបច្ចេកទេសបង្រៀន និងវិធី-សាស្ត្រសម្របសម្រួល | វគ្គ | | | | | | |
| ៣.២ | ចូលរួមវគ្គបំប៉នបច្ចេកទេសបង្រៀន | វគ្គ | | | | | | |
| ៣.៣ | រៀបចំក្រុមឪពុកម្តាយ អាណាព្យាបាលកុមារនៅតាមសហគមន៍ក្នុងភូមិ | ក្រុម | | | | | | |
| ៣.៤ | ផ្សព្វផ្សាយគម្រោងសកម្មភាពអប់រំឪពុកម្តាយអាណាព្យាបាល | ប្រជុំ | | | | | | |
| ៣.៥ | ប្រជុំប្រចាំខែរបស់គណៈកម្មការគ្រប់គ្រងគម្រោងសកម្មភាព | ប្រជុំ | | | | | | |
| **៤** | **ការរាយការណ៍ និងព័ត៌មានត្រឡប់** | | | | | | | |
| ៤.១ | រៀបចំរបាយការណ៍ប្រចាំខែស្តីពីការបង្រៀន និងការរៀន | របាយការណ៍ | | | | | | |
| ៤.២ | រៀបចំរបាយការណ៍ស្តីពីការគ្រប់គ្រងដំណើរការវគ្គបណ្តុះបណ្តាល | របាយការណ៍ | | | | | | |
| ៤.៣ | រៀបចំបញ្ជីប្រមូលទិន្នន័យសម្រាប់ក្រុមឪពុកម្តាយអាណាព្យាបាល | បញ្ជី | | | | | | |

| ល.រ | សកម្មភាព | លទ្ធផល | | | ចំនួនអ្នកទទួលផល | | បញ្ហាប្រឈម | ដំណោះស្រាយ ឬអនុសាសន៍ |
|---|---|---|---|---|---|---|---|---|
| | | ឯកតា | គ្រោង | សម្រេចបាន | សរុប | ស្រី | | |
| ៥ | **សម្ភារប្រើប្រាស់ និងសង្ហារិម** | | | | | | | |
| ៥.១ | ផ្តល់កន្ទេល ឬតង់សម្រាប់ជាកម្រាល | គ្រឿង | | | | | | |
| ៥.២ | ផ្តល់សម្ភារសិក្សា | កញ្ចប់ | | | | | | |

ថ្ងៃ..........................ខែ..................ឆ្នាំ..............ព.ស...........

ថ្ងៃទី...........ខែ.............ឆ្នាំ.............

**ជ.គណៈកម្មការគ្រប់គ្រង**

**ប្រធាន**

ថ្ងៃ...........................ខែ..................ឆ្នាំ...............ព.ស..............

ថ្ងៃទី...............ខែ............ឆ្នាំ..............

**បានឃើញ និងឯកភាព**

**មេឃុំ ចៅសង្កាត់**



# ជំពូកទី៤

# យន្តការគាំទ្រគម្រោងសកម្មភាព
# អប់រំឪពុកម្ដាយ អាណាព្យាបាល




រូបភាព ការប្រជុំរវាងក្រុមប្រឹក្សាឃុំកំភន់ ស្រុកសេសាន ខេត្តស្ទឹងត្រែង ជាមួយប្រតិភូនៃគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍន៍កុមារតូចស្វែងយល់ពីយន្តការគាំទ្រ

# ជំពូកទី៤
# យន្តការគាំទ្រគម្រោងសកម្មភាពអប់រំឪពុកម្ដាយ អាណាព្យាបាល

ដំណើរការអប់រំឪពុកម្ដាយ អាណាព្យាបាលក្នុងការគាំពារ និងអភិវឌ្ឍន៍កុមារតូចអាយុក្រោម៦ឆ្នាំ ត្រូវការគាំទ្រ និងសម្របសម្រួលពីរដ្ឋបាលរាជធានី ខេត្ត មន្ទីរជំនាញ រដ្ឋបាលក្រុង ស្រុក ខណ្ឌ (ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គមក្រុង ស្រុក ខណ្ឌ) ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋក្នុងសហគមន៍ ដែលរួមមានដូចខាងក្រោម៖។

## ៤.១. រដ្ឋបាលរាជធានី ខេត្ត

អង្គភាពពាក់ព័ន្ធមួយចំនួនរបស់រដ្ឋបាលរាជធានី ខេត្ត មានតួនាទី ភារកិច្ចដូចខាងក្រោម៖

- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររាជធានី ខេត្ត ផ្ដល់យោបល់ដល់ក្រុមការងារកសាងផែនការរាជធានី ខេត្ត អំពីគម្រោង សកម្មភាពអប់រំឪពុកម្ដាយ អាណាព្យាបាល ក្នុងការគាំពារ និងអភិវឌ្ឍន៍កុមារតូច និងកៀរគរធនធានជាមួយដៃគូអភិវឌ្ឍន៍ក្នុងការជួយគាំទ្រគម្រោង សកម្មភាពអប់រំឪពុកម្ដាយ អាណាព្យាបាល
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររាជធានី ខេត្ត ត្រូវសម្របសម្រួលជាមួយក្រសួង ស្ថាប័ន មន្ទីរ និងដៃគូអភិវឌ្ឍន៍ ក្នុងការបណ្ដុះបណ្ដាលបច្ចេកទេសដល់ក្រុមឪពុកម្ដាយបង្គោល និងអ្នកសម្របសម្រួលអំពីការរីកលូតលាស់ និងការចិញ្ចឹមបីបាច់កុមារតូចក្រោមអាយុ៦ឆ្នាំ
- ក្រុមការងារកសាងផែនការរាជធានី ខេត្ត ត្រូវដាក់បញ្ចូលគម្រោង សកម្មភាពអប់រំឪពុកម្ដាយ អាណាព្យាបាល ស្ដីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូចក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត
- ទីចាត់ការផែនការ និងវិនិយោគត្រូវផ្ដល់បច្ចេកទេសដល់រដ្ឋបាលឃុំ សង្កាត់ក្នុងការរៀបចំគម្រោងសកម្មភាពអប់រំឪពុកម្ដាយ អាណាព្យាបាល អាយុ៦ឆ្នាំ ក្នុងការគាំពារ និងអភិវឌ្ឍន៍កុមារតូច និងសម្របសម្រួលជាមួយមន្ទីរជំនាញក្នុងការបណ្ដុះបណ្ដាលបច្ចេកទេស និងចំណេះដឹងស្ដីអំពីកុមារតូច និងការរីកលូតលាស់របស់កុមារតូច គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររាជធានី ខេត្ត និងទីចាត់ការផែនការ និងវិនិយោគចុះតាមដាន ត្រួតពិនិត្យ និងផ្ដល់យោបល់ក្នុងការគ្រប់គ្រងអនុវត្តគម្រោងសកម្មភាព
- ទីចាត់ការផែនការ និងវិនិយោគត្រូវសម្របសម្រួលជាមួយរតនាគារ និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ដើម្បីជួយគាំទ្រឃុំ សង្កាត់ក្នុងការប្រើប្រាស់ និងគ្រប់គ្រងថវិកាសម្រាប់ការអនុវត្តគម្រោងសកម្មភាពអប់រំឪពុកម្ដាយ អាណាព្យាបាល ស្ដីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច។

## ៤.២.មន្ទីរអប់រំ យុវជន និងកីឡា

មន្ទីរអប់រំ យុវជន និងកីឡាមានតួនាទី ភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការបណ្តុះបណ្តាល ការបំប៉ន និងជំនួយបច្ចេកទេសផ្សេងៗដល់ក្រុមឪពុកម្តាយបង្គោល ដើម្បីដាក់បញ្ចូលក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរ និងស្នើសុំការគាំទ្រថវិកាពីក្រសួងអប់រំ យុវជន និងកីឡា ឬរដ្ឋបាលរាជធានី ខេត្ត
- រៀបចំវគ្គបណ្តុះបណ្តាលបច្ចេកទេស និងវគ្គបំប៉នដល់ក្រុមឪពុកម្តាយបង្គោល និងអ្នកសម្របសម្រួល ព្រមទាំងផ្តល់សម្ភារចាំបាច់មួយចំនួនក្នុងការសម្របសម្រួលវគ្គ
- សហការជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងការជំរុញការិយាល័យអប់រំយុវជន និងកីឡា ដើម្បីជួយរដ្ឋបាលឃុំ សង្កាត់ ក្នុងការរៀបចំបង្កើត និងកែលម្អក្រុមឪពុកម្តាយបង្គោល រួមទាំងការជ្រើសរើសអ្នកសម្របសម្រួល
- តាមដាន ត្រួតពិនិត្យបច្ចេកទេសសម្របសម្រួលក្រុមឪពុកម្តាយ អាណាព្យាបាល និងផ្តល់អនុសាសន៍ដើម្បីកែលម្អ
- សហការជាមួយទីចាត់ការផែនការ និងវិនិយោគ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររាជធានី ខេត្ត និងរតនាគាររាជធានី ខេត្ត ក្នុងការដោះស្រាយបញ្ហានានា ដូចជាការកំណត់ និងទូទាត់ប្រាក់ឧបត្ថម្ភ ឪពុកម្តាយបង្គោល និងសម្របសម្រួល។

## ៤.៣.មន្ទីរកិច្ចការនារី

មន្ទីរកិច្ចការនារីរាជធានី ខេត្ត មានតួនាទី ភារកិច្ចគាំទ្រដូចខាងក្រោម៖

- ផ្សព្វផ្សាយអប់រំដល់ឪពុកម្តាយបង្គោល និងអ្នកសម្របសម្រួល ស្តីអំពីសារៈប្រយោជន៍នៃការថែទាំ និងការចិញ្ចឹមបីបាច់កុមារតូចបែបវិជ្ជមាន ការគាំពារនិងការអភិវឌ្ឍន៍កុមារតូច ព្រមទាំងការយល់ដឹងអំពីកុមារតូច និងសិទ្ធិរបស់កុមារ
- លើកកម្ពស់សមត្ថភាពក្រុមប្រឹក្សាឃុំ សង្កាត់ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ក្រុមឪពុកម្តាយបង្គោល ឪពុកម្តាយផ្ទាល់ អាណាព្យាបាលលើការអភិវឌ្ឍ ការថែទាំ និងការចិញ្ចឹមបីបាច់កុមារតូចក្រោមអាយុ៦ឆ្នាំតាមបែបវិជ្ជមាន
- សហការជាមួយគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររាជធានី ខេត្ត មន្ទីរ និងការិយាល័យជំនាញពាក់ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិលចូលរួមដោះស្រាយបញ្ហាពាក់ព័ន្ធ ការអនុវត្តសកម្មភាពរបស់ក្រុមឪពុកម្តាយបង្គោល និងអ្នកសម្របសម្រួលតាមការស្នើសុំរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារឃុំ សង្កាត់ និងពង្រឹងបណ្តាញការងារលើកកម្ពស់សមភាពយេនឌ័រ និងបរិយាបន្នក្នុងវិស័យចិញ្ចឹមបីបាច់ និងអប់រំកុមារតូចក្រោមអាយុ៦ឆ្នាំ
- ផ្តល់ជាសម្ភារបង្រៀន និងផ្សព្វផ្សាយក្នុងសហគមន៍ដល់ក្រុមឪពុកម្តាយបង្គោល និងអ្នកសម្របសម្រួល។

## ៤.៤.មន្ទីរសុខាភិបាល

មន្ទីរសុខាភិបាលរាជធានី ខេត្ត មានតួនាទី ភារកិច្ច ដូចខាងក្រោម៖

- លើកកម្ពស់សមត្ថភាពក្រុមប្រឹក្សាឃុំ សង្កាត់ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ក្រុមឪពុកម្តាយបង្គោល ឪពុកម្តាយផ្ទាល់ អាណាព្យាបាលលើការការថែទាំ ការផ្តល់អាហារូបត្ថម្ភ ការចាក់វ៉ាក់សាំង និងចិញ្ចឹមបីបាច់កុមារតូច
- ផ្សព្វផ្សាយអប់រំដល់ឪពុកម្តាយ អាណាព្យាបាលដែលមានកុមារតូចក្រោមអាយុ៦ឆ្នាំ ស្តីពីសារៈប្រយោជន៍នៃការថែទាំ និងការបំបៅដោះតែមួយមុខគត់ដល់ទារកអាយុក្រោម៦ខែ ការគាំពារ និង ការអភិវឌ្ឍន៍កុមារតូច ការយល់ដឹងអំពីកុមារតូច និងសិទ្ធិរបស់កុមារផងដែរ
- លើកកម្ពស់សមត្ថភាពក្រុមប្រឹក្សាឃុំ សង្កាត់ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ក្រុមឪពុកម្តាយបង្គោល ឪពុកម្តាយផ្ទាល់ អាណាព្យាបាលលើការអភិវឌ្ឍ ការថែទាំ និងការចិញ្ចឹមបីបាច់កុមារតូចក្រោមអាយុ៦ឆ្នាំតាមបែបវិជ្ជមាន
- សហការជាមួយគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររាជធានី ខេត្ត មន្ទីរ និងការិយាល័យជំនាញពាក់ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិលចូលរួមដោះស្រាយបញ្ហាពាក់ព័ន្ធនៃការអនុម័តសកម្មភាពរបស់ក្រុមឪពុកម្តាយបង្គោល និងអ្នកសម្របសម្រួលតាមការស្នើសុំរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និងពង្រឹងបណ្តាញការងារលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យចិញ្ចឹមបីបាច់ និងអប់រំកុមារតូចក្រោមអាយុ៦ឆ្នាំ

## ៤.៥.មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានតួនាទី ភារកិច្ចដូចខាងក្រោម៖

- ផ្សព្វផ្សាយ និងផ្តល់ចំណេះដឹងអំពីការបង្ការទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់ និងការលើកកម្ពស់ការថែទាំកុមារនៅតាមគ្រួសារ និងសហគមន៍
- ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីអំពើហិង្សាលើកុមារ និងកិច្ចការពារកុមារ
- ផ្សព្វផ្សាយអប់រំដល់ក្រុមឪពុកម្តាយ អាណាព្យាបាល ដែលមានកូនបានធ្វើសមាហរណកម្មចេញពីមណ្ឌលថែទាំអំពីការចិញ្ចឹមកូនបែបវិជ្ជមាន ការការពារកុមារ ការអភិវឌ្ឍកុមារ និងសិទ្ធិកុមារ
- សហការជាមួយគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររាជធានី ខេត្ត មន្ទីរ និងការិយាល័យជំនាញពាក់ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិលចូលរួមដោះស្រាយបញ្ហាពាក់ព័ន្ធ ការអនុវត្តសកម្មភាពរបស់ក្រុមឪពុកម្តាយបង្គោល និងអ្នកសម្របសម្រួលតាមការស្នើសុំរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារឃុំ សង្កាត់ និងពង្រឹងបណ្តាញការងារលើកកម្ពស់សមភាពយេនឌ័រ និងបរិយាបន្នក្នុងវិស័យចិញ្ចឹមបីបាច់ និងអប់រំកុមារតូចក្រោមអាយុ៦ឆ្នាំ។

## ៤.៦. រដ្ឋបាលក្រុង ស្រុក ខណ្ឌ

អង្គភាពពាក់ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ មានតួនាទី ភារកិច្ចដូចខាងក្រោម៖

- ក្រុមការងារកសាងផែនការក្រុង ស្រុក ខណ្ឌ ត្រូវដាក់បញ្ចូលគម្រោងសកម្មភាពអប់រំឪពុកម្ដាយ អាណាព្យាបាលទៅក្នុងផែនការអភិវឌ្ឍន៍ និងវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ
- ការិយាល័យជំនាញពាក់ព័ន្ធត្រូវផ្ដល់បច្ចេកទេសដល់រដ្ឋបាលឃុំ សង្កាត់ ក្នុងការគ្រប់គ្រងដំណើរការរៀបចំគម្រោងសកម្មភាពអប់រំសម្រាប់ឪពុកម្ដាយ អាណាព្យាបាល ស្ដីអំពីការថែទាំ និងការចិញ្ចឹមកុមារតូច
- ការិយាល័យអប់រំ យុវជន និងកីឡា ត្រូវបណ្ដុះបណ្ដាលបច្ចេកទេសដល់ឪពុកម្ដាយបង្គោល និងអ្នកសម្របសម្រួល
- ចុះតាមដាន ត្រួតពិនិត្យ និងផ្ដល់យោបល់លើការគ្រប់គ្រងគម្រោងសកម្មភាពអប់រំឪពុកម្ដាយ
- ចុះតាមដាន ត្រួតពិនិត្យ និងចូលរួមដោះស្រាយបញ្ហាដូចជាភាពមិនទៀងទាត់ក្នុងការផ្ដល់ប្រាក់ឧបត្ថម្ភដល់ក្រុមឪពុកម្ដាយបង្គោល និងជួយសម្របសម្រួលការចូលរួមរបស់ឪពុកម្ដាយ និងអាណាព្យាបាលរបស់កុមារតូច
- គណៈកម្មាធិកាពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្រុង ស្រុក ខណ្ឌផ្ដល់យោបល់ដល់ក្រុមការងារកសាងផែនការក្រុង ស្រុក ខណ្ឌ អំពីគម្រោងសកម្មភាពអប់រំឪពុកម្ដាយ អាណាព្យាបាលដែលមានកុមារស្ដីអំពីការថែទាំ និងចិញ្ចឹមបីបាច់កុមារតូចដែលមានអាយុក្រោម៦ឆ្នាំ ព្រមទាំងចុះតាមដាន និងកៀរគធនធានពីដៃគូអភិវឌ្ឍន៍ក្នុងការជួយគាំទ្រគម្រោងសកម្មភាពអប់រំឪពុកម្ដាយ ដែលមាន កុមារតូចក្រោមអាយុ៦ឆ្នាំ
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្រុង ស្រុក ខណ្ឌ ត្រូវសម្របសម្រួលជាមួយការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ក្នុងការបណ្ដុះបណ្ដាលបច្ចេកទេសសម្របសម្រួល និងផ្ដល់ជាសម្ភារដល់ឪពុកម្ដាយបង្គោល និងអ្នកសម្របសម្រួល។

## ៤.៧.ការិយាល័យអប់រំ យុវជន និងកីឡា

ការិយាល័យអប់រំយុវជន និងកីឡា មានតួនាទី ភារកិច្ចដូចខាងក្រោម៖

- រៀបចំវគ្គបណ្ដុះបណ្ដាលបច្ចេកទេសដល់ឪពុកម្ដាយ បង្គោល និងអ្នកសម្របសម្រួល ព្រមទាំងផ្ដល់សម្ភារបង្រៀន និងរៀន និងឯកសារពាក់ព័ន្ធ
- ផ្ដល់យោបល់ និងគាំទ្រផ្នែកបច្ចេកទេសក្នុងការរៀបចំបង្កើតក្រុមឪពុកម្ដាយ អាណាព្យាបាល ឪពុកម្ដាយបង្គោល និងអ្នកសម្របសម្រួលក្នុងការរៀបចំសកម្មភាពការងារ
- តាមដាន ត្រួតពិនិត្យបច្ចេកទេស និងសម្របសម្រួលក្រុមឪពុកម្ដាយ អាណាព្យាបាល ឪពុកម្ដាយបង្គោល និងអ្នកសម្របសម្រួល រួមទាំងផ្ដល់អនុសាសន៍កែលម្អ

- សហការជាមួយគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ការិយាល័យផែនការ និងគាំទ្រ ឃុំ សង្កាត់ ការិយាល័យពាក់ព័ន្ធក្នុងការដោះស្រាយបញ្ហាដូចជា ការផ្តល់ប្រាក់ឧបត្ថម្ភ ការសម្រប សម្រួលរបស់ក្រុមឪពុកម្តាយបង្គោល និងការចូលរួមរបស់ឪពុកម្តាយក្នុងសហគមន៍។

## ៤.៨.ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម

ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គមមានតួនាទី ភារកិច្ចដូចខាងក្រោម៖

- ផ្តល់ការគាំទ្រគម្រោងសកម្មភាពអប់រំឪពុកម្តាយ អាណាព្យាបាល ដែលបានលើកឡើងក្នុងផែនការ អភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់
- ផ្តល់យោបល់ និងជំនួយបច្ចេកទេសដល់ក្រុមប្រឹក្សាឃុំ សង្កាត់ គ.ក.ន.ក. និងអ្នកទទួលបន្ទុកកិច្ចការ នារី និងកុមារឃុំ សង្កាត់ ឪពុកម្តាយបង្គោលក្នុងការលើកកម្ពស់សុខភាពមាតា និងទារក
- តាមដាន ត្រួតពិនិត្យ វាយតម្លៃការអនុវត្តសកម្មភាពលើកកម្ពស់សុខភាពមាតា និងទារក
- គាំទ្រការអនុវត្តសកម្មភាពគម្រោងសកម្មភាពអប់រំឪពុកម្តាយ អាណាព្យាបាលក្នុងការគាំពារ និង អភិវឌ្ឍន៍កុមារតូចអាយុក្រោម៦ឆ្នាំ សម្រាប់ឃុំ សង្កាត់។

## ៤.៩.ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល

ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលមានតួនាទី ភារកិច្ចដូចខាងក្រោម៖

- ចូលរួមផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការរៀបចំគម្រោងផែនការក្រុមអប់រំសម្រាប់ឪពុក ម្តាយ អាណាព្យាបាល ដែលមានកុមារតូចអាយុក្រោម៦ឆ្នាំ ឱ្យបានកាន់តែសកម្ម
- ផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុក្នុងការគាំទ្រសកម្មភាពក្រុម និងប្រាក់ឧបត្ថម្ភផ្សេងៗដល់កម្មវិធីអប់រំឪពុក ម្តាយ។ បណ្តុះបណ្តាល ការបំប៉នដល់ក្រុមឪពុកម្តាយបង្គោលឱ្យកាន់តែប្រសើរ
- ជួយពង្រឹងសមត្ថភាពអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ គណៈកម្មាធិការទទួលបន្ទុក កិច្ចការនារី និងកុមារឃុំ សង្កាត់ ដើម្បីគ្រប់គ្រង និងសម្របសម្រួលក្រុមឪពុកម្តាយបង្គោលឱ្យកាន់តែ មានប្រសិទ្ធភាព
- ចូលរួមត្រួតពិនិត្យ និងវាយតម្លៃសកម្មភាព ក៏ដូចជាគម្រោងសកម្មភាពទាំងមូល និងផ្តល់មតិយោបល់ កែលម្អ។

## ៤.១០.ប្រជាពលរដ្ឋ

- ចូលរួមយ៉ាងសកម្ម និងដោយស្ម័គ្រចិត្តក្នុងកិច្ចប្រជុំពិគ្រោះយោបល់ វគ្គផ្សព្វផ្សាយ ការកំណត់បញ្ហា និងតម្រូវការអប់រំសម្រាប់ឪពុកម្តាយ អាណាព្យាបាលក្នុងការគាំពារ និងអភិវឌ្ឍន៍កុមារតូចអាយុ ក្រោម៦ឆ្នាំ ក្នុងភូមិ
- ចូលរួមយ៉ាងសកម្មក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃសកម្មភាពនៃការអប់រំសម្រាប់ឪពុកម្តាយ អាណាព្យាបាល។



រូបភាព ការធ្វើទស្សនៈកិច្ចសិក្សារបស់ប្រតិភូនៃគណៈកម្មការជាតិគាំពារ និងអភិវឌ្ឍន៍កុមារតូច
នៅឃុំសាមឃួយ ស្រុកសេសាន  ខេត្តស្ទឹងត្រែង

គាំទ្រដោយ៖

PLAN INTERNATIONAL